**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០២១/០៣/២០០៩ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០០៩

**ជម្រាបមក**

**ឯកឧត្តម លោកជំទាវ ជាតំណាងរាស្ត្រ ចំនួន ១៧ រូប**

**កម្មវត្ថុ** : រឿងទាក់ទងនឹងសំណើសុំពិនិត្យធម្មនុញ្ញភាព លើសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ( គ.ជ.ប ) ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៨ និងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ១០០/០០៥/២០០៨ កបធ.ច ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០០៨

**យោង** : លិខិតរបស់ឯកឧត្តម លោកជំទាវ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម លោកជំទាវ ជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០០៩ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យសំណើរបស់ឯកឧត្តម លោកជំទាវរួចហើយ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា ពុំអាចលើកយកសំណើរបស់ឯកឧត្តម លោកជំទាវមកពិភាក្សាបានឡើយ ពីព្រោះសំណើនេះមិនចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានចែងក្នុងមាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ ថ្មី នៃច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

សូមឯកឧត្តម លោកជំទាវទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**